# បុណ្យភ្ជុំបិណ្ឌ



ដោយៈ លោកស្រី **បណ្ឌិត ជា វណ្ណី**
ប្រធានផ្នែកធម្មសាស្ត្រនិងចរិយាសាស្ត្រនៃ
វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

ពិធីបុណ្យភ្ជុំបិណ្ឌ គឺជាពិធីបុណ្យមួយក្នុងចំណោមពិធីបុណ្យធំៗនានានៃព្រះរាជពិធីទ្វាទសមាស ដែលមាននៅក្នុងប្រពៃណីទំនៀមទម្លាប់នៃប្រទេសកម្ពុជា។ ប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជាតាំងពីបុរាណរៀងមក (ពុំដឹងពេលណាច្បាស់លាស់) តែងតែប្រារព្ធពិធីបុណ្យនេះមិនដែលអាក់ខានឡើយ គឺចាប់ពីថ្ងៃ ១រោច ខែភទ្របទ រហូតដល់ថ្ងៃទី ១៥រោច ដែលមានរយៈពេល១៥ថ្ងៃ។ ក្នុងរយៈពេល១៥ថ្ងៃនេះ គេហៅថាបិណ្ឌទី១, បិណ្ឌទី២...រហូតដល់ថ្ងៃបញ្ចប់ គឺជាថ្ងៃ "ភ្ជុំបិណ្ឌ"។ បុណ្យភ្ជុំបិណ្ឌ ត្រូវបានធ្វើឡើងតាមបែបព្រះពុទ្ធសាសនា។ ជារៀងរាល់ឆ្នាំ នៅពេលដល់វេលាដែលត្រូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ បងប្អូនកូនចៅជាសាច់ញាតិសន្តានទាំងអស់ ទោះបីជារស់នៅទីជិត ឬទីឆ្ងាយក្តី តែងតែនាំគ្នាធ្វើដំណើរត្រឡប់ទៅស្រុកកំណើត ដើម្បីទៅជួបជុំជាមួយឪពុកម្តាយដោយមានជូនជាថវិកា និសម្ភារប្រើប្រាស់ផ្សេងៗដល់អ្នកមានគុណ និងចាស់ទុំដែលជាសាច់ញាតិ ក៏ដូចជានាំគ្នារៀបចំម្ហូបអាហារ ផ្កាភ្ញី យកទៅប្រគេនព្រះសង្ឃដែលគង់នៅតាមទីវត្តអារាមផងដែរ។

តើពិធីបុណ្យភ្ជុំបិណ្ឌមានប្រវត្តិសាវតាយ៉ាងដូចម្តេច? ហេតុអ្វីបានជាគេប្រារព្ធពិធីបុណ្យនេះ? តើពិធីបុណ្យនេះគេធ្វើឡើងនៅពេលណា? តើគេប្រារព្ធធ្វើយ៉ាងដូចម្តេចខ្លះ? ហេតុអ្វីបានជាពិធីបុណ្យនេះ គេសូត្របរាភវសូត្រ គេធ្វើពិធីបោះបាយបិណ្ឌ ធ្វើពិធីពូនភ្នំខ្សាច់ និងជឿថាមានប្រេត? តើពិធីបុណ្យនេះមានទំនាក់ទំនងជាមួយនិងបុណ្យចូលវស្សាដែរឬទេ?

## ប្រវត្តិបុណ្យភ្ជុំបិណ្ឌ

ពាក្យថា "ភ្ជុំបិណ្ឌ" មកពីពាក្យ "ភ្ជុំ" រួមគ្នាជាមួយពាក្យ "បិណ្ឌ" ដែលមានន័យថា ជាការប្រមូលផ្តុំ ឬប្រជុំបិណ្ឌ គឺធ្វើឱ្យជុំ, ឱ្យជួបជុំគ្នា, ឱ្យប្រជុំគ្នា, រួបរួមគ្នា, សាមគ្គីគ្នា។

បើតាមវចនានុក្រម សម្តេចព្រះសង្ឃរាជ *ជួន ណាត* លោកបានពន្យល់ថា៖ ភ្ជុំ (កិ.) ធ្វើឱ្យជុំ, ឱ្យជួបជុំគ្នា, ឱ្យប្រជុំគ្នា : ភ្ជុំគ្នា, ភ្ជុំពល ។ ភ្ជុំជាតក ឬ ភ្ជុំជាតិ រួបរួមជាតិកំណើតពួកអ្នកដែលអន្ទោលមកកើតជួបគ្នា

ដោយព្រះសព្វញ្ញុពុទ្ធទ្រង់សញ្ញាណឃើញច្បាស់ហើយទ្រង់ត្រាស់សម្តែងប្រាប់។ ភ្ជុំបិណ្ឌ (ម.ព.បិណ្ឌ)។ បិណ្ឌ បិន-ឌៈ ឬ បិន សំ. បា. (ន.) ការប្រមូលឱ្យមូល ឬពូនឱ្យជាដុំ, ដុំ; ការចិញ្ចឹមជីវិត។ ខ្មែរយើងប្រើពាក្យនេះជាឈ្មោះនៃពិធីធ្វើទានមួយ (តាមប្រពៃណីរបស់ប្រទេស) ដែលធ្វើបានពីត្រឹមថ្ងៃទី១រោច ខែភទ្របទទៅដល់ថ្ងៃខែដាច់ (១៥ថ្ងៃ)...ហៅថា បុណ្យកាន់បិណ្ឌ ឬបុណ្យដាក់បិណ្ឌ, ហៅខ្លីត្រឹមតែ កាន់បិណ្ឌ ឬដាក់បិណ្ឌ ក៏បាន; ថ្ងៃ ១៥រោច ខែភទ្របទ ហៅថា ថ្ងៃភ្ជុំបិណ្ឌ..., ពួកឧបាសកទាយកតែងទៅប្រជុំគ្នាធ្វើទានឯវត្តមិនសូវមានអ្នកណាមួយខានឡើយ។ ដូច្នេះយើងអាចសម្គាល់ពាក្យនេះតាមវិធីងាយបានថា គឺជា "ការប្រជុំ ឬប្រមូលផ្តុំដុំបាយ" (ការពូតដុំបាយជាដុំៗដែលយើងហៅថា "បាយបិណ្ឌ") ។

សរុបមក ភ្ជុំបិណ្ឌ គឺជាការប្រជុំគ្នារបស់អ្នកស្រុកភូមិខ្មែរ ដើម្បីរៀបចំ ប្រមែប្រមូលបាយ ឬដុំបាយដាក់ស្រាក់ យកទៅវត្ត ប្រគេនព្រះសង្ឃ ឬធ្វើជាពំនូតបាយ ឬដុំបាយដាក់ចានយកទៅវត្ត ដើម្បីប្រគេនព្រះសង្ឃសូត្រធម៌ ឧទ្ទិសកុសលដល់ ខ្មោចទាំងឡាយ ដែលបានស្លាប់ទៅ ដែលអស់លោកទាំងនោះអាចជា បងប្អូនជីដូនជីតា ឬញាតកាទាំងប្រាំពីរសណ្តាន។

បើតាមតម្រាចារតាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើង បានបង្ហាញថាពិធីបុណ្យភ្ជុំបិណ្ឌគឺកើតមានតាំងពីបុរាណកាលមកម៉្លេះ ប៉ុន្តែកាលពីសម័យមុនគេមិនហៅថាបុណ្យភ្ជុំទេ ដោយនៅក្នុងពិធីនេះគេមានបែងចែកចេញជាពីរដំណាក់កាល។ ដំណាក់កាលដំបូង គឺគេចាប់ផ្តើមធ្វើចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៤រោច គឺជាវារកភត្ត (ភត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់។ ចំណែកមួយដំណាក់កាលទៀតគេធ្វើនៅថ្ងៃ១៥រោច ដែលគេហៅថាបុណ្យភ្ជុំ ហើយពិធីបុណ្យទាំងពីរដំណាក់កាលនេះ បច្ចុប្បន្នត្រូវបានគេបញ្ចូលគ្នា ដោយហៅកាត់ថា ពិធីបុណ្យភ្ជុំបិណ្ឌ។

ពាក់ព័ន្ធនឹងពិធីបុណ្យភ្ជុំបិណ្ឌនេះ មានគម្ពីរ៣ ដែលបកស្រាយពីពិធីបុណ្យកាន់បិណ្ឌនេះគឺះ

**១. គម្ពីរ បេតវត្ថុ៖** បកស្រាយពីរឿងប្រេត គម្ពីរអានិសង្សបិណ្ឌនិយាយអំពីផលនៃការធ្វើបុណ្យ

**២. គម្ពីរពិទ្យាធរ ឬគម្ពីរវិជ្ជាធរៈ៖** តំណាលអំពីប្រពៃណីរបស់ខ្មែរ ដែលមានជាប់ទាក់ទងដល់សព្វថ្ងៃ

**៣. គម្ពីរវិមានវត្ថុ ៖** គម្ពីរធម្មបទ ជា ដើម...។

បើតាមគម្ពីរ "ពិទ្យាធរ ឬវិជ្ជាធរ" មានតំណាលថា កាលនោះមាន ព្រះថេរមួយអង្គព្រះនាម **ឧបគុត្តត្ថេរ** លោកមានអំណាចមានឥទ្ធិពលច្រើនណាស់ លោកក៏បាននិមន្តទៅធ្វើទស្សនកិច្ចនៅស្ថាននរក ដែលពោរពេញដោយភ្លើងឆេះយ៉ាងសន្ធោរសន្ធៅក្តៅខ្លាំង ប៉ុន្តែដោយឥទ្ធិពលរបស់លោក ក៏មានលេចចេញនូវផ្កាឈូករត្ន័មួយធំប៉ុនកងរាជរថ រួចលោកក៏គង់នៅលើផ្កាឈូកនោះ ហើយផ្កាឈូកនោះ ក៏ហោះកាត់ស្ថាននរក ដែលធ្វើឱ្យព្រះអង្គត្រជាក់ស្រួល មិនបណ្តាលឱ្យប៉ះពាល់ដល់ភ្លើងកម្តៅស្ថាននរកឡើយ។ រីឯពួកសត្វនរកវិញគ្រាន់តែដឹងថា ព្រះ **ឧបគុត្តត្ថេរ** លោកនិមន្តទៅភ្លាមក៏ធ្វើឱ្យពួកសត្វនរកទាំងនោះមានការភ្ញាក់ផ្អើលជាខ្លាំង។ ពួកសត្វនរកទាំងនោះ មានការកោតខ្លាចនូវភាពអស្ចារ្យនេះយ៉ាងខ្លាំង ក៏នាំគ្នាចុះមកអបអរសាទរ ហើយសួរអំពីឫទ្ធិបារមីរបស់ព្រះអង្គ លោកក៏បានពន្យល់ សម្តែងធម៌ទេសនាឱ្យពួកសត្វនរកទាំងនោះស្តាប់។ ក្រោយមកលោកក៏បានលា

ត្រលប់មកស្ថានមនុស្សវិញ ហើយពួកសត្វនរកទាំងនោះបានផ្តាំផ្ញើថា៖ "*ទូលព្រះបង្គំទាំងអស់គ្នាសព្វថ្ងៃនេះលំបាកវេទនាណាស់ ណាមួយកម្តៅភ្លើងនរក ណាអត់អាហារ មិនដែលមានសាច់សាលោហិតណាលើកយកអាហារភោជន ឬបច្ច័យបួនមកឧបត្ថម្ភខ្ញុំម្តងណាទេ គឺខ្ញុំអត់ឃ្លាននោះខ្លាំងណាស់ រោគាព្យាធិ ជំងឺតម្កាត់ក៏មានច្រើនដែរ អីចឹងបើព្រះតេជគុណនិមន្តទៅស្ថានមនុស្សលោកវិញ សូមព្រះតេជគុណមេត្តាផ្សព្វផ្សាយឱ្យបងប្អូនញាតិមិត្ត ម៉ែ ឪ ជីដូន ជីតា របស់ខ្ញុំឱ្យធ្វើបុណ្យ និមន្តព្រះសង្ឃមកដាក់បិណ្ឌ ឬកាន់បិណ្ឌផង រួចហើយផ្សព្វផ្សាយពរសព្វសាធុការផល្លានិសង្ឃ បុណ្យដាក់បិណ្ឌដល់ទូលព្រះបង្គំទាំងអស់គ្នាផង ដើម្បីឱ្យបានផលជួបឧបត្ថម្ភឱ្យបានឆ្អែតស្កប់ស្កល់បាត់ទុក្ខវេទនាតទៅ*"។ **ព្រះឧបគុត្តត្ថេរ** ក៏នាំយកបណ្តាំទាំងនោះទៅក្រាបបង្គំទូលស្តេចនាពេលនោះទៅ។ គ្រាន់តែថ្វាយព្រះពរប៉ុណ្ណឹងស្តេចក៏ធ្វើជាចុតហ្មាយ ហើយផ្សព្វផ្សាយដល់ប្រជារាស្ត្រគ្រប់ៗគ្នាក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យប្រជារាស្ត្រទាំងអស់ធ្វើបុណ្យដាក់បិណ្ឌ ឬកាន់បិណ្ឌនៅក្នុងរដូវវស្សាដោយផ្តាំផ្ញើទៀតថា ***ត្រូវធ្វើឱ្យចំថ្ងៃ១រោច ខែភទ្របទ រហូតដល់ថ្ងៃ១៥រោច ខែភទ្របទ ឬដាច់ខែ។*** ដោយហេតុនេះហើយដែលនាំឱ្យមានពិធីកាន់បិណ្ឌជាប្រពៃណី តាំងពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ។

បើតាមសៀវភៅ «***ពិធីប្រចាំដប់ពីរខែ***» របស់អ្នកស្រី **ពេជ្រ សល់** សរសេរថា ផ្អែកតាមសិលាចារិករបស់ព្រះបាទយសោវរ្ម័ន គ្រងរាជសម្បត្តិរវាង គ.ស. ៨៨៩ ដល់៩១០ ព្រះអង្គបានសាងអាវាសជាច្រើន ហើយទ្រង់តែងធ្វើពិធីបូជាបាយបិណ្ឌជារៀងរាល់ខែ ដើម្បីឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធអ្នកស្លាប់ក្នុងចម្បាំង និងចំពោះខ្មោចទាំងឡាយដែលគ្មានបងប្អូនគ្រួសារញាតិសន្តាន។ ទាក់ទងនឹងការថយចុះនៃកិច្ចទំនុកបម្រុងនិច្ចភត្តភិក្ខុសង្ឃ ក្នុងរដូវចូលវស្សាបីខែ ដែលប្តូរមកនៅត្រឹមពិធីបុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌរយៈពេលតែ ១៥ថ្ងៃ នាសម័យនេះឯកសារមួយចំនួនកត់ត្រាថា គឺចាប់ពីរជ្ជកាលព្រះករុណាបរមកោដ្ឋ ព្រះអង្គឌួង រវាងពុទ្ធសករាជ ២៣៩១-២៤០៤ ដែលត្រូវនឹងគ្រិស្តសករាជ ១៨៤៨-១៨៥៩។

## ការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ

ចំពោះបុណ្យបិណ្ឌភ្ជុំនេះ បុរាណាចារ្យរាជបណ្ឌិតខ្មែរយើងបានរៀបចំរយៈពេល១៥ថ្ងៃ ដោយចាប់គិតពីថ្ងៃទី០១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ ជាពិធីមួយសម្រាប់ឧទ្ទិសកុសលទៅដល់បេតជនញាតិដែលបានស្លាប់ទៅ។ នៅក្នុងរយៈពេល១៤ថ្ងៃ នៃការកាន់បិណ្ឌ ឬដាក់បិណ្ឌនេះ ពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ ជាពិសេសក្រុមនីមួយៗដែលបានរៀបចំជាក្រុម ដើម្បីរៀបចំធ្វើយាគូ ឬធ្វើភត្តាហារយកទៅវត្តប្រគនព្រះសង្ឃ។ ពេលទូងស្គរចំណាំវស្សា អ្នកនៅក្នុងក្រុមវេននីមួយៗត្រូវចាប់ផ្តើមធ្វើចង្ហាន់ ហើយយាយតាចាស់ៗក្នុងក្រុមវេនប្រមូលនំនែករៀបចំបាយបិណ្ឌនិងបាយបិត្តបូរ។ រៀបចំរួចហើយ ចាស់ៗត្រូវនាំគ្នាទៅវត្តស្តាប់លោកសូត្រថ្វាយបង្គំធម៌សុខោ និងធម៌បរាភវសូត្រ។ ចំណែកឯកូនចៅដែលនៅផ្ទះ នាំគ្នារៀបចំម្ហូបអាហារ។ លុះដល់ពេលព្រឹកព្រាងអរុណោទ័យ កូនចៅត្រូវនាំគ្នារៀបចំខ្លួន កណ្តៀត យួរ កាន់ ទូល រែក ចង្ហាន់យកទៅវត្ត។ នៅក្នុងបរិវេណវត្ត លោកអាចារ្យត្រូវរៀបចំពីធីរាប់បាត្រនៅលើឧបដ្ឋានសាលា។ បន្ទាប់មកលោកអាចារ្យជាប្រធាន ត្រូវនាំពុទ្ធបរិស័ទវេរចង្ហាន់ប្រគេនព្រះសង្ឃ វេរបាយបិត្តបូរ។ល។ លុះដល់ពេលព្រះសង្ឃធ្វើបត្តានុមោទនគាថាចប់ មេវេនក្រុមនីមួយៗត្រូវរៀបចំម្ហូបអាហារ ចំណីចូលគំនាប់ជូនលោកអាចារ្យវត្ត ព្រមទាំងចាត់ចែងភោជនាហារទទួលភ្ញៀវដែលអញ្ជើញទៅបុណ្យនៅក្នុងថ្ងៃវេនរបស់ខ្លួននោះផងដែរ។ ការប្រគេនចង្ហាន់ដល់ព្រះសង្ឃ ត្រូវបានធ្វើឡើងដើម្បីឧទ្ទិសកុសលជូនទៅជីដូនជីតា ឪពុកម្តាយ បងប្អូន និងញាតិទាំង៧សណ្តាន ដែលបានស្លាប់ក្លាយ

ជាប្រេត ហើយត្រូវបានជាប់ឃុំនៅក្នុងនរក។ ក្នុងការបើកទ្វាននរកនេះ ប្រេតខ្លះមានឱកាសរួចផុតពីការជាប់ទារុណកម្មនៅនរក ខណៈដែលប្រេតខ្លះទៀតត្រូវបានគេដោះលែងឱ្យនៅក្រៅនរកជាបណ្តោះអាសន្នដើម្បីទៅទទួលយកនូវចំណី និងកុសលផលបុណ្យដែលកូនចៅបានឧទ្ទិសឱ្យ ហើយនឹងត្រូវត្រឡប់ទៅទទួលទុក្ខវេទនានៅក្នុងនរកបន្តទៀត បន្ទាប់ពីពិធីភ្ជុំបិណ្ឌនេះត្រូវបានបញ្ចប់។ ចំពោះញាតិសណ្ដានដែលមិនបាននៅក្នុងនរកក៏ដោយក្តី ក៏ត្រូវបានគេចាត់ទុកថា អាចទទួលបាននូវកុសលពីការឧទ្ទិសក្នុងពិធីបុណ្យនេះផងដែរ។

ក្នុងថ្ងៃបុណ្យភ្ជុំ មានរៀបចំកញ្ចប់ចតុប្បច្ច័យ (ស៊ង) ប្រគេនគ្រប់ភិក្ខុសាមណេរ ហើយគណៈកម្មការវត្តបានចាត់ចែងនំអន្សម នំគម និងបាយបិណ្ឌបូរឱ្យទៅសិស្សគណទុកប្រគេនភិក្ខុសាមណេរតាមចំណែកសម្រាប់ធ្វើចង្ហាន់នៅព្រឹកថ្ងៃបន្ទាប់។ ម្យ៉ាងវិញទៀត ថ្ងៃបុណ្យភ្ជុំបិណ្ឌនេះ កាលពីសម័យបុរាណ គេមានលេងល្បែងប្រណាំង ក្របី សេះ ចាប់ពី២-៣គូ ទៅតាមតំបន់រៀងៗខ្លួន[ត្រូវការអំណះអំណាង] ដើម្បីអបអរនៅក្នុងថ្ងៃបុណ្យឆ្លងបង្ហើយ។ លើសពីនេះទៅទៀតក្របី សេះ និងរបស់ដែលត្រូវប្រកួត ត្រូវគេបានតុបតែងលំអដោយប្រេង លាបពណ៌របើបរលោង មានពាក់ប្រឡៅ កណ្ដឹងត្រដោក ឬចង្រ្កងជាដើម។ រីឯកន្លែងខ្លះទៀតមានលេងល្បែងផ្សេងៗខុសពីនេះ។ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ ទំនៀមទម្លាប់នេះចេះតែបាត់ទៅៗ រួញថយបន្តិចម្តងៗ សាសនាកាន់តែកន្លងវែងទៅ នាំឱ្យការប្រកាន់ខ្ជាប់ស្ទើរតែបាត់បង់អស់ផងដែរ។

ប្រជាជនខ្មែរ ក៏តែងតែចងចាំ និងយល់គ្រប់ៗគ្នាថា ពិធីបុណ្យភ្ជុំបិណ្ឌ គឺជាការធ្វើបុណ្យដាក់បិណ្ឌដើម្បីឧទ្ទិសដល់បេតបុគ្គល ជាឪពុក ម្តាយ បងប្អូន ឬញាតិសន្តានទាំងឡាយ ដែលបានចែកស្ថានទៅ ហើយមិនដឹងជាទៅចាប់កំណើតជាអ្វី។ ប៉ុន្តែបើតាមអត្ថបទរបស់ លោក **សុង ស៊ីវ** វិញ ការធ្វើបុណ្យភ្ជុំបិណ្ឌ ពុំមែនមានន័យតែប៉ុណ្ណឹងទេ គឺលោកបានបកស្រាយដោយលើកយកអត្ថន័យថាៈ

- ដើម្បីឧទ្ទិសកុសលចំពោះបេតបុគ្គល ឬប្រេតបុគ្គល (ពាក្យ "បេត" ជាពាក្យបាលី ឯពាក្យ "ប្រេត" ជាពាក្យសំស្រ្កឹត) ដើម្បីឱ្យបានសេចក្តីសុខចម្រើន មានសិរីសួស្តីដែលកើតពីផលទានរបស់ខ្លួន។

- ដើម្បីបង្កើតសាមគ្គីរបស់ជាតិ គឺការស្រុះស្រួលគ្នាទាំងពេលវេលាកំណត់ទាំងការធ្វើនំគម អន្សមពេញទូទាំងព្រះរាជាណាចក្រកម្ពុជា យើងក៏អាចកត់សម្គាល់នូវពាក្យមួយទៀតថា "បុណ្យសែនដូនតា" ដែលជាពាក្យសាមញ្ញសម្រាប់ប្រជារាស្រ្តខ្លះ ព្រោះថាពាក្យទាំងពីរគឺមានន័យដូចគ្នា។

កាលពីសម័យបុរាណកាល គេធ្វើពិធីបុណ្យនេះ គឺដើម្បីរៀបចំធ្វើសង្ឃភត្ត ទំនុកបម្រុងព្រះសង្ឃដែលគង់ចាំវស្សាក្នុងវត្តរយៈពេល៣ខែ ចាប់ពីថ្ងៃចូលវស្សារហូតដល់ថ្ងៃចេញវស្សា។ នៅក្នុងចំណោកកាលបុរាណបានចារថា ដោយនៅក្នុងរដូវវស្សាមានភ្លៀងធ្លាក់ជោកជាំ រលឹមពព្រិច ធ្វើឱ្យមានការលំបាកដល់ព្រះសង្ឃក្នុងពេលធ្វើគោចរបិណ្ឌបាត។ ហេតុដូច្នេះ ទើបបណ្ឌាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃរហូតដល់ថ្ងៃចេញវស្សា។ ម្យ៉ាងវិញទៀត នៅក្នុងពិធីបុណ្យនេះ គឺធ្វើឡើងដើម្បីផ្សាយឧទ្ទិសកុសលដល់ពពួកបេតជនញាតិ និងញាតិទាំង៧សណ្ដាន ព្រមទាំងតំណញាតិច្រើនមហាកប្បនោះផងដែរ តាមរយៈអនុភាពនៃសង្ឃគតាទក្ខិណាទាន ដែលរស់រងទុក្ខវេទនា កើតជាប្រេតមានកម្មពៀរ ជាប់ទោសធ្ងន់ រងកម្មក្រហល់ក្រហាយអត់ឃ្លានទាំងអស់នោះ បានរួចផុតពីក្តីលំបាកសោកសៅ។

តាមទំនៀមចាស់ពីបរមបុរាណមក នៅថ្ងៃ១កើត ខែអស្សុជនេះ ពុទ្ធបរិស័ទបាននាំគ្នាធ្វើពិធីជូនដំណើរព្រលឹងដូនតាត្រឡប់ទៅទីឋានដើមវិញ បន្ទាប់ពីបុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌអស់រយៈពេល១៥ថ្ងៃមក គឺគេនាំគ្នាក្រោកពីយប់រៀបចំក្បូនដើមចេក ផ្ទុកដោយស្រូវអង្ករ អាហារចំណី នំនែកផ្លែឈើច្រើនមុខ ហើយយកទៅបណ្តែតតាមទន្លេស្ទឹងបឹងបួ នៅក្នុងភូមិស្រុក នៅពេលព្រឹកព្រលឹម។ ក្បូននេះ ជួនកាលគេធ្វើជារៀងទូក ឬសំពៅ ដោយមានដុតទៀនធូប និងតុបតែងលំអដោយទង់ជ្វាលា និងផ្កាភ្ញីចម្រុះពណ៌ផងដែរ។

## រដូវបុណ្យភ្ជុំបិណ្ឌ

ចាប់តាំងពីសម័យបុរាណកាលរហូតមកដល់បច្ចុប្បន្ននេះ ពិធីបុណ្យភ្ជុំបិណ្ឌនេះ គេតែងតែប្រារព្ធធ្វើនៅក្នុងរដូវវស្សា ព្រោះនៅក្នុងរដូវនេះ ពពួកប្រេតអាចមានឱកាសច្រើនក្នុងការស្វែងរកចំណីអាហារជាងរដូវណាៗទាំងអស់។ ម្យ៉ាងវិញទៀតនៅក្នុងវស្សានរដូវ អាហាររបស់ពួកប្រេត មានដូចជា ភក់ជ្រាំ ស្លេស្ម កំហាកសាកសព និងកាកសំណល់អសោចិ៍ សម្បូរនៅក្នុងខែភ្លៀងធ្លាក់ពព្រិច។ នៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌរយៈពេល១៥ថ្ងៃនេះ មានពពួកបេតជន(ពួកប្រេត) សាច់ញាតិទាំងប្រាំពីរសណ្តាន ព្រមទាំងតំណាញាតិច្រើនមហាកប្បដែលអត់ឃ្លានអាហារអស់រយៈពេលជាច្រើនខែមកហើយនោះ ត្រូវបានរួចផុតពីការឃុំឃាំង និងអនុញ្ញាតឱ្យមកស្វែងរកសាច់ញាតិនៅតាមវត្តអារាមផ្សេងៗ ដែលនាំយកចំណីអាហារផ្សេងៗ មកឧទ្ទិសកុសលឱ្យខ្លួន។ ម្យ៉ាងវិញទៀត បើតាមសម្តីចាស់ៗបុរាណនិយាយតៗគ្នាថា ក្នុងរយៈពេល១៥ថ្ងៃ បើពពួកបេតជនទាំងអស់នោះដើរស្វែងរកញាតិចំនួន៧វត្ត នៅតែមិនឃើញនោះ ពពួកប្រេតទាំងអស់នោះនឹងស្រែកយំទន្ទ្រាំជើង ព្រោះតែការខកបំណង និងភាពស្រេកឃ្លានក្រហល់ក្រហាយក្នុងចិត្ត។ ជាពិសេសពពួកបេតជនទាំងអស់នោះ នឹងដេរដាក់បណ្តាសាដល់សាច់ញាតិ កូនចៅក៏មាន។

## ការបោះបាយបិណ្ឌ

នៅព្រលឹមម៉ោង៤ព្រឹក ប្រជាពលរដ្ឋតែងតែនាំគ្នាដើរទៅវត្តអារ៉ាមនានាដែលស្ថិតនៅក្នុងភូមិ ឬនៅក្បែរផ្ទះរបស់ខ្លួន ជាមួយនឹងនំចំណីដែលធ្វើរួចជាស្រេចដើម្បីយកទៅវត្ត។ ការបោះបាយបិណ្ឌជាជំនឿអរូបិយមួយផងដែរ ដែលប្រជាពលរដ្ឋខ្មែរយើងនិយមធ្វើជារៀងរាល់ព្រឹក ដើម្បីបញ្ជូន ឬឧទ្ទិសកុសលឱ្យទៅញាតិសន្តានសាច់សាលោហិតដែលបានចែកឋានទៅបរលោក។ ការបោះបាយបិណ្ឌ(ការបោះដុំបាយ) ជាសកម្មភាពមួយដែលមិនទាន់មានឯកភាពគ្នានៅក្នុងសង្គមពុទ្ធសាសនិកនៅឡើយ ដោយអ្នកខ្លះបានចាត់ទុកការបោះបិណ្ឌជាកិច្ចដ៏សំខាន់មួយមិនអាចខានបាននៅក្នុងរដូវបុណ្យកាន់បិណ្ឌនេះ ខណៈដែលអ្នកខ្លះបានអះអាង និងរិះគន់ថាការបោះបាយបិណ្ឌជាទង្វើមិនត្រឹមត្រូវ ជាភាពខ្ជះខ្ជាយជាការធ្វើមិនគោរពទានជាដើម។ អ្នកដែលជឿថា បោះបាយបិណ្ឌមានប្រយោជន៍គិតថា បោះបាយបិណ្ឌគឺបោះឱ្យពួកប្រេត (ហេតុនេះទើបនៅតំបន់ខ្លះមិនហៅបាយបិណ្ឌទេ តែហៅថាបាយប្រេត)។ ចំណែកអ្នកពុទ្ធនិយមខ្លះទៀតបានអះអាងថា ការបោះបាយបិណ្ឌជាការធ្វើទានមិនត្រឹមត្រូវតាមការបង្រៀនរបស់ព្រះពុទ្ធឡើយ។

ពាក្យថា បិណ្ឌ បានន័យថា ពំនូតបាយ ដែលគេឧទ្ទិសដល់ខ្មោចដែលបានស្លាប់ទៅ។ គេដាក់បាយបិណ្ឌក្នុងថាស១ យកទៅវត្ត។ នៅពាក់កណ្តាល បាយបិណ្ឌ មានបាយ បិតបូរ ដែលគេដាក់លើជើងពានមួយ។ បាយបិតបូរ ដូចគ្នានឹងបាយបិណ្ឌដែរ ប៉ុន្តែគេធ្វើរាងស្រួចដូចសាជី ហើយធ្វើគំរបស្លឹកចេកគ្របពីលើ ដោយ

ចោះកំពូលទុកដោតទៀនធូប និងផ្កា។ នៅតំបន់ខ្លះ គេធ្វើបាយបិណ្ឌដាក់ក្នុងកន្ទោងចំនួន៨ព័ទ្ធជុំវិញបាយបិតបូរ។ ក្នុងកន្ទោងនីមួយៗមានពំនូតបាយបិណ្ឌពី១ ទៅ១៥ដុំ។ គេនិយមទៅបោះបាយបិណ្ឌនៅឯវត្តវេលាទៀបភ្លឺ ដោយគេជឿថា ធ្វើបែបនេះពួកប្រេតទទួល បានដោយផ្ទាល់។ ព្រមគ្នាជាមួយនឹងព្រះសង្ឃសូត្រធម៌ ពួកពុទ្ធបរិស័ទទាំងអស់ កាន់ចានបាយបិណ្ឌរៀងៗខ្លួន ដើរតម្រង់ ទៅព្រះវិហារដើម្បីធ្វើពិធីបោះបាយបិណ្ឌ។ ពេលដើរជុំវិញព្រះវិហារនោះ គេត្រូវដុតធូបប្រាំសរសៃ ដាក់នៅលើចានបាយបិណ្ឌ។ ដើរបានមួយជុំ អាចារ្យប្រកាសថា អនុមោទនាលើកអើយ!! ។ ពុទ្ធបរិស័ទទាំងអស់គ្នាស្រែកថាៈ សាធុ!។ រួចគេចាប់យកបាយ១ដុំដាក់ទៅលើដី ឬបោះទៅទីឆ្ងាយ ហើយដោតធូបមួយសរសៃ ឬផ្កាផ្សេងៗ១ទងនៅលើដីដែរ។ គេធ្វើបែបនេះ គម្រប់៣ដង ។ រីឯបាយបិណ្ឌនិងធូបនៅនៅសល់ គេនាំយកតាមអាចារ្យ ដែលអញ្ជើញចេញទៅក្រៅវត្ត ទៅកាន់ទីដែលនៅជិតខ្ទមអ្នកតា ឬក្រោមដើមឈើធំៗហើយអុជធូប និងចាក់បាយបិណ្ឌទាំងអស់នោះ ទៅលើដីដើម្បីឱ្យខ្មោចដែលគ្មានបងប្អូន ធ្វើបុណ្យបញ្ជូនឱ្យ ។ អាចារ្យហាមមិនឱ្យលាងចាននិងដៃនៅទីនោះឡើយ ។ បន្ទាប់មក អាចារ្យ ធ្វើពិធីបង្សុកូល ប្រួចទឹកលើនំចំណី និងបាយបិណ្ឌឱ្យប្រេត ទាំងនោះដែលមកចាំទទួលដែរ តែគ្មានញាតិសណ្ដានឧទ្ទិសឱ្យ។

ក្រៅពីតង្វាយផ្សេងៗនៅក្នុងសាលាបុណ្យនៃវត្ត គេនាំគ្នារៀបចំតុបតែងធ្វើផ្កាបិណ្ឌ ដែលមានរាងមូលស្រួចដូចសាជី។ នៅលើកំពូលផ្កាបិណ្ឌ គេធ្វើរូបហង្សទ្រទៀន ដែលគេអុជរាល់យប់នៅពេលកាន់បិណ្ឌ។ គេថា ផ្កាបិណ្ឌ នេះជាតង្វាយចំពោះព្រះចូឡាមណីចេតីយ។ មុនថ្ងៃ ភ្ជុំបិណ្ឌ១ថ្ងៃ គឺថ្ងៃ១៤រោចនៅតាមផ្ទះនីមួយៗ គេនិយមធ្វើនំអន្សម នំគមសម្រាប់យកទៅប្រគេនលោក ឧទ្ទិសដល់អ្នកដែលបានស្លាប់ទៅហើយផង ចែកចាយដល់អ្នកជិតខាង ឬមិត្តភក្តិផង។ នៅពេលយប់នៃថ្ងៃនោះ នៅឯវត្តមានពិធីបង្សុកូលជូនវិញ្ញាណក្ខន្ធ អ្នកដែលបានបាត់បង់ជីវិតទៅហើយ មានការសូត្រធម៌ និងការសម្តែងធម្មទេសនារហូតដល់ភ្លឺ។ លុះស្អែកឡើង ថ្ងៃ១៥រោចខែភទ្របទ ដែលជាថ្ងៃចុងក្រោយនៃពិធីភ្ជុំបិណ្ឌ ហើយដែលជាថ្ងៃសំខាន់ជាងគេ អ្នកស្រុកគ្រប់ផ្ទះនាំគ្នាទៅប្រជុំនៅវត្ត។ អ្នកខ្លះកាន់បាយបិណ្ឌ បាយបិតបូរ ខ្លះកាន់នំអន្សម នំគមនិងនំចំណីផ្សេងៗ ខ្លះទៀតកាន់ចានស្រាក់ដាក់ចង្ហាន់ទៅប្រគេនព្រះសង្ឃ។ ក្រៅពីពិធីភ្ជុំបិណ្ឌដែលធ្វើនៅវត្ត មានពិធីសែនព្រេននៅតាមផ្ទះនៅវេលាព្រលប់នៃថ្ងៃបង្ហើយនោះដែរ។ នៅកណ្ដាល ផ្ទះល្វែង គេក្រាលកន្ទេលដាក់ខ្នើយនៅក្បាលកន្ទេល រួចយកសំពត់សមកក្រាលពីលើខ្នើយនិងកន្ទេលនោះ។ ពេលនោះ គេរៀបថាស ម្ហូបនំចំណី បាយបិណ្ឌ បាយបិតបូរ ផ្តិលទឹក ពានស្លាម្លូ ពានបារី។ គ្រួសារទាំងអស់មកអង្គុយជុំវិញរណ្ដាប់ ទាំងនោះ ហើយមេគ្រួសារអុជទៀនធូបអញ្ជើញវិញ្ញាណក្ខន្ធដូនតាមកពិសាក្រយ៉ានេះ ហើយសុំឱ្យជួយថែរក្សាកូនចៅ នៅរស់ឱ្យបានសុខសប្បាយផង។ លុះព្រឹកឡើង គេរៀបដាក់នំចំណីក្នុងកូនទូកធ្វើអំពីដើមចេកហើយ បណ្ដែតលើទឹក (ពិធីបណ្ដែតប្រទីបសម្រាប់ដូនតា) ដើម្បីជូនដំណើរដូនតាទៅវិញ។

ពិធីបណ្តែតប្រទីបសម្រាប់ដូនតាមានតាំងពីបុរាណកាលមករហូតដល់សព្វថ្ងៃ គឺមានប្រជាជនក្នុងភូមិស្រុកមួយ ដែលនៅប្រកាន់ខ្ជាប់ពិធីសែនព្រេន គេបានជួបជុំនៅពេលរសៀលនៃថ្ងៃបុណ្យភ្ជុំ ដោយអ្នកស្រុករៀបចំតុបតែងលម្អទូកតូចៗដែលគេច្នៃពី ដើមគរ ដើមស្នោ ស្រទបចេក ដើមចេក ឬដើមកំប្លោក មួយឬពីរយ៉ាងស្អាតសមសួន។ បន្ទាប់មកគេក៏មានរៀបចំ ប្រកភោគផល សម្លៀកបំពាក់ និងម្ហូបអាហារ មាន ស្រូវ អង្ករ ល្ងរ សណ្ដែក គ្រឿងទេស ត្រីងៀត ត្រីឆ្អើរ នំគម នំអន្សម ម្លូរ ស្លា បារី កំបោ ជាកញ្ចប់តូចៗសមល្មម ដែលទូកតូចៗទាំងនោះ អាចចំណុះបាន (បរិមាណជានិមិត្តរូបនៃស្បៀងអាហារ និងភោគផលខ្មែរ)។ ឯលើទូកទៀត

សោត គេមានតុបតែងលម្អដោយភ្លើងពណ៌ ទៀន ធូប ចង្កៀង ផ្កាធ្វើពីក្រដាស ឬក្រណាត់ចម្រុះពណ៌។ ក្រោយពីគេរៀបចំទូក បានស្អាតរួចរាល់ហើយ គេក៏យកទូកនិងរបស់របរទាំងនោះ ទៅដាក់នៅកណ្ដាលផ្ទះល្វែងដោយ មានក្រាលកន្ទេល ដាក់ខ្នើយនៅក្បាលកន្ទេល រួចយកសំពត់សមកក្រាលពីលើខ្នើយ និងកន្ទេលនោះ។ ពេលនោះ គេរៀបថាស ម្ហូបនំចំណី បាយបិណ្ឌ បាយបិតបូរ ផ្តិលទឹក ពានស្លាម្លូ ពានបារី។ គ្រួសារទាំងអស់មកអង្គុយជុំវិញរណ្តាប់ ទាំងនោះ ហើយមេគ្រួសារអុជទៀនធូប អញ្ជើញវិញ្ញាណក្ខន្ធដូនតា មកពិសាក្រយ៉ានេះ ហើយសុំឱ្យជួយថែរក្សា កូនចៅ នៅរស់ឱ្យបានសុខសប្បាយ។ លុះព្រឹកឡើង គេរៀបដាក់នំចំណី ក្នុងកូនទូកធ្វើអំពីដើមចេក ហើយ បណ្តែតលើទឹក ដើម្បីជូនដំណើរជូនតាទៅវិញ ។ មុននឹងទៅដល់កំពង់ទឹក ក្នុងវេលាម៉ោង ៣ទៀបភ្លឺ អ្នកស្រុកភូមិទាំងអស់ បាននាំគ្នាក្រោកឡើង ប្រកូកប្រកាសគ្នីគ្នា ដើម្បីយកទូកជូនតាទៅប្រជុំគ្នានៅកណ្តាលភូមិ បន្ទាប់មកម៉ោងប្រហែល៤ភ្លឺនៃយប់ថ្ងៃភ្ជុំបិណ្ឌ គេក៏នាំគ្នាដង្ហែទូកទាំងនោះ យកទៅបន្តែតនៅមាត់ទន្លេ ដែថ្ងៃនេះជាថ្ងៃដែលសប្បាយបំផុតសម្រាប់អ្នកភូមិ។

## បរាភវសូត្រ

បរាភវសូត្រ គឺជាការរំឭកដាស់តឿនដល់ពុទ្ធបរិស័ទទាំងឡាយ ឱ្យខិតខំវៀរចាកអបាយមុខទាំងពួង ដូចជាគ្គលដែលមានវ័យចំណាស់ពេក ហើយយកមនុស្សក្មេងជាប្រពន្ធប្តី ភាពជាបុគ្គលអកត្តញ្ញូ មិនដឹងគុណឪពុកម្តាយ អ្នកលេងល្បែង៣ប្រការ រួមមាន ស្រី ស្រា ល្បែង ភាពខ្ជិលច្រអូស ការសេពគប់អសប្បុរស ការប្រកាន់ធម៌អគតិ ពោលគឺព្រះពុទ្ធទ្រង់បានបង្រៀនពីហេតុផលសាមញ្ញៗ និងជាក់ស្តែងដែលជាដើមហេតុនាំមកនូវក្តីវិនាស។ បុគ្គលដែលឈ្លាសវៃតែងតែត្រងត្រាប់ស្តាប់ធម៌នេះដោយយកចិត្តទុកដាក់ជាទីបំផុត ព្រោះបើបុគ្គលណាដែលបានយល់ និងត្រាប់តាមការហោមឃាត់ នៃធម៌នេះហើយ បុគ្គលនោះតែងតែជួបនូវសេចក្តីសុខចម្រើនជានិច្ច។ ធម៌នេះតែងតែត្រូវបានព្រះសង្ឃសូត្រនៅក្នុងព្រះវិហារជារៀងរាល់ថ្ងៃនាពេលទៀបភ្លឺ នៅក្នុងអំឡុងពេលបុណ្យកាន់បិណ្ឌ។ បរាភវសូត្រមានន័យថា «មាត្រាដែលពោលពីធម្មជាតិដែលគ្មានក្តីចម្រើន ឬធម៌ជាហេតុនាំឱ្យមានក្តីវិនាស»។ សូត្រនេះមាននៅក្នុងគម្ពីរសុត្តន្តបិដកខុទ្ទកនិកាយ សុត្តនិបាត តតិយភាគទី៥៤ ទំព័រទី៣៦។ ធម៌នេះ ធ្វើឱ្យអ្នកស្តាប់បានដឹងច្បាស់ពីមូលហេតុដែលនាំឱ្យវិនាស ហើយឱ្យគេជៀសវាង ដើម្បីគេចឱ្យផុតពីក្តីវិនាស ហើយប្រសិនបើគេមិនបានស្តាប់ធម៌នេះ គេអាចនឹងមិនដឹងពីហេតុដែលនាំឱ្យវិនាសហេតុនេះ អាចនឹងប្រព្រឹត្តខុសជាហេតុនាំឱ្យវិនាសទៅវិញ។

## ការពូនភ្នំខ្សាច់ក្នុងពិធីបុណ្យភ្ជុំបិណ្ឌ

ទាក់ទិននឹងជំនឿដែលពុទ្ធបរិស័ទលើកឡើងអំពីការពូនភ្នំខ្សាច់ នៅអំឡុងពេលបុណ្យភ្ជុំបិណ្ឌនេះ វាជាជំនឿមួយដែលខ្មែរយើងទូទៅយល់ថា វាល្អ ហើយមានប្រយោជន៍ទើបពួកគាត់ធ្វើ។ ការពូនភ្នំខ្សាច់ ដោយមានដាក់លុយទៅតាមភ្នំខ្សាច់នីមួយៗ ព្រមទាំងអុជធូបទៀនបួងសួងនោះ គឺដើម្បីស្មាលាកំហុសបាបមួយចំនួនដែលខ្លួនបានសាងឡើង ដោយមិនបានចាប់អារម្មណ៍នាពេលកន្លងមក។ ការពូនភ្នំខ្សាច់នេះក៏ជាការឧទ្ទិសកុសលមួយជូនដល់ឧបការីជនទាំងឡាយដែលបានលាចាកលោកផងដែរ។ សូមបញ្ជាក់ថា ភ្នំខ្សាច់ ឬចេតិយខ្សាច់នេះ បើហៅតាមភាសាបាលីថា *វាលុកចេតិយ* គឺចេតិយខ្សាច់ដែលគេគរជាគំនរ និងត្រូវបានគេពូនជារាងចេតិយដើម្បីឧទ្ទិសដល់ព្រះចូឡាមុនីចេតិយរបស់ព្រះពុទ្ធអង្គ។ ចូឡាមណីចេតិ គឺជាចេតិយដែលតម្កល់នូវព្រះ

កេសា និងព្រះចង្កូមកែវរបស់ព្រះពុទ្ធ ដែលស្ថិតនៅឯស្ថានតាវត្តិង្សឯណោះ។ ស្ថានតាវត្តិង្ស គឺជាស្ថានសួគ៌មួយក្នុងចំណោមស្ថានទេវលោកជាច្រើនទៀត ដែលគ្រប់គ្រងដោយព្រះឥន្ទ្រ។ កាលពីព្រះពុទ្ធអង្គចេញសាងព្រះផ្នួសនៅព្រះជន្ម២៩ឆ្នាំ ព្រះអង្គក៏បានកាត់ព្រះកេសាដោយខ្លួនឯង ហើយព្រះកេសានោះ ត្រូវបានទេវតានាំយកទៅតម្កល់ទុកនៅឯចូឡាមណីចេតិយ។ ចំណែកឯព្រះចង្កូមកែវ ត្រូវបានទេវតាបាននាំទៅតម្កល់ទុកក្នុងចេតិយនេះដូចគ្នា គឺនៅពេលដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វាន ហើយព្រះសពត្រូវបានរំលាយដោយព្រះអគ្គី។ ដូច្នេះភ្នំខ្សាច់ដែលត្រូវបានធ្វើឡើង គឺតំណាងឱ្យព្រះចេតិយដែលបញ្ចុះនូវព្រះកេសា និងព្រះចង្កូមកែវនៃព្រះសម្មាសម្ពុទ្ធនេះឯង។ ការពូនភ្នំខ្សាច់នេះ ចាស់បុរាណយើងបានពន្យល់ថា គឺជាការរំឭកដល់ព្រះចូឡាមណីចេតិយ។ ការរំឭកដល់ព្រះចូឡាមណីចេតិយ គឺជាការរំឭកដល់ព្រះកេសា និងព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ។ ការរំឭកដល់ព្រះសារីរិកធាតុ គឺដូចជាការរំឭកដល់តួអង្គផ្ទាល់នៃព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គមានគុណដ៏អនេកប្បការចំពោះសត្វលោក ពោលគឺគុណទាំងបី រួមមាន បញ្ញាគុណ ករុណាគុណ និងវិសុទ្ធិគុណ។ ការរំឭកដល់គុណព្រះពុទ្ធនេះហើយ ដែលធ្វើឱ្យយើងកើតនូវចិត្តសទ្ធាជ្រះថ្លាចំពោះព្រះអង្គ ដែលជាហេតុនាំឱ្យកើតកុសលផលបុណ្យ។

ម្យ៉ាងវិញទៀត ដោយអំណាចនៃការពូនភ្នំខ្សាច់ ឧបកិច្ចដល់ព្រះចូឡាមណីចេតិយនេះ ក៏អាចឱ្យអ្នកទាំងឡាយដែលចូលរួមពូននោះ ធ្វើនូវការសុំអធ្យាស្រ័យដល់ពពួកសត្វ និងមនុស្ស ព្រមទាំងទេវតាទាំងពួងក្នុងចក្រវាឡទាំងមូលឱ្យលើកលែង និងអហោសកម្មដល់ខ្លួន ដែលធ្លាប់ប្រព្រឹត្តនូវអំពើជាអកុសល ដល់សត្វលោកទាំងនោះក្នុងអតីតជាតិ ដោយអចេតនាណាមួយ។ ប៉ុន្តែប្រសិនបើបាបកម្ម ដែលយើងធ្លាប់ធ្វើលើអ្នកដទៃឱ្យរងការឈឺចាប់ដោយចេតនា និងចិត្តឫស្យានោះយើងពុំអាចសុំឱ្យដាច់កម្មពៀរ ឬបាបកម្ម ដោយគ្រាន់តែគោរពចំពោះភ្នំខ្សាច់នោះទេ។ បើយើងធ្វើបាបគេដោយចេតនា ហើយយើងអាចសុំលាងជម្រះបាបកម្ម ឬកម្មពៀរទាំងនោះ ដោយគ្រាន់បូជាចំពោះភ្នំខ្សាច់ប៉ុណ្ណឹង អីចឹងវាដូចជាអយុត្តិធម៌ពេកហើយសម្រាប់អ្នករងគ្រោះព្រោះច្បាប់ធម្មជាតិមិនតម្រូវឱ្យយើងមានសិទ្ធិរបៀបនេះឡើយ។ ជាងនេះទៅទៀត ដោយអានុភាពនៃសទ្ធាជ្រះថ្លាក្នុងការពូនភ្នំខ្សាច់ រំឭកដល់ព្រះពុទ្ធអង្គ យើងក៏អាចប្រាថ្នាសុំនូវសិរីសួស្តីទាំងឡាយឱ្យកើតមានដល់ក្រុមគ្រួសារ និងសហគមន៍ផងដែរ។ ប៉ុន្តែ បើទោះបីជាយើងផ្សងដូច្នេះក៏ពិតមែន តែយើងក៏ត្រូវតែខិតខំបំពេញកិច្ចទាំងឡាយណាដែលនាំឱ្យរីកចម្រើនដែរ មិនមែនតាំងសេចក្តីប្រាថ្នាឡើងបួងសួង ហើយក៏ដេករង់ចាំលទ្ធផលនោះដែរ។ ចាស់បុរាណតែងពោលទុកមកថា បើយើងបានពូនភ្នំខ្សាច់ គឺដូចជាយើងបានចូលរួមសាងសង់នូវព្រះចេតិយ៍ថ្វាយព្រះសម្មាសម្ពុទ្ធផ្ទាល់អីចឹងដែរ ហើយការរំឭកដល់ព្រះចូឡាមណីចេតិយក៏ដូចជាការបូជាដល់ព្រះសម្មាសម្ពុទ្ធផ្ទាល់ដូចគ្នា។

**ប្រេត**

**ប្រេត** បើអានតាមសំនៀងខ្មែរ អានថា **ប្រែត** គឺជាពាក្យខ្ចីមកពីភាសាសំស្ក្រឹត ចំណែកពាក្យខ្ចីមកពីភាសាបាលីវិញ ហៅថា **បេត** អានថា **ប៉េតៈ** ។ អត្ថន័យដើមរបស់ពាក្យ **ប្រេត** គឺជាមនុស្សស្លាប់ ឬព្រលឹងខ្មោច។ នៅក្នុងវចនានុក្រមខ្មែរ *ប្រេត ត. ទ. អ. ថ. ប្រែត សំ.; បា. (ន.) (បេត) សត្វកើតក្នុងអបាយភូមិពួកមួយៈ ពួកប្រេត។ គុ. អ្នកដែលធ្វើមរណកាលទៅកាន់បរលោកហើយ។*

ក្រោយមកពុទ្ធសាសនាមហាយានបានជ្រាបទៅដល់ប្រទេសចិន ជនជាតិចិនបានបកប្រែពាក្យ ប្រេត ពីភាសាសំស្ក្រឹតទៅជាភាសាចិនថា "អេគុយ" (egui) ដែលមានន័យផ្សេងថា "ខ្មោចស្រេកឃ្លាន" ដែលជាប់អត្ថន័យនៅក្នុងគម្ពីរព្រះត្រៃបិដក និងផ្នត់គំនិតខ្មែរ និងសាសន៍ផ្សេងៗទៀតដែលកាន់ពុទ្ធសាសនានិកាយថេរវាទ រហូតមកដល់សព្វថ្ងៃ។ ទស្សនៈអំពីខ្មោច ឬព្រលឹង នៅក្នុងវប្បធម៌របស់ជនជាតិឥណ្ឌា និងជនជាតិចិនដូចគ្នា។ ដូច្នេះការបកប្រែភាសា និងការបង្រៀនទ្រឹស្តីពុទ្ធសាសនាក៏មានការប្រែប្រួលដែលនាំឱ្យកើតមានទស្សនៈថ្មីស្រឡាងនៅជំនាន់ក្រោយៗទៀត ។

បើតាមគម្ពីរព្រះពុទ្ធសាសនាបានចែងថា *ប្រេត គឺមនុស្សដែលស្លាប់ទៅតែងទៅកើតទីផ្សេងៗតាមកម្មរបស់ខ្លួន។ មនុស្សចិត្តអាក្រក់ ដែលបានធ្វើបាបកម្មផ្សេងៗ លុះស្លាប់ទៅតែងតែកើតជាប្រេត៤ប្រភេទ គឺប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម ប្រេតស្រេកឃ្លានអាហារជានិច្ច ប្រេតដែលភ្លើងឆេះជានិច្ច និងប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសទៅឱ្យ។* គេតែងនិយមជ្រើសរើសចំថ្ងៃរនោចខែភទ្របទ ព្រោះពេលវេលានោះ ព្រះចន្ទពុំសូវមានពន្លឺ ហើយចេះតែងងឹតទៅៗ ព្រោះឱកាសនោះហើយ ដែលយមរាជដោះលែងពួកប្រេតទាំងនោះឱ្យមករស់នៅលាយឡំជាមួយមនុស្ស ចាំទទួលភោគផលដែលបងប្អូនញាតិសន្តានឧទ្ទិសឱ្យ ព្រោះពួកប្រេតខ្លាចពន្លឺណាស់។ ប្រសិនបើរយៈពេល១៥ថ្ងៃ ពួកប្រេតដើររកគ្រប់វត្តពុំមានឃើញបងប្អូនញាតិសន្តានណាធ្វើបុណ្យបញ្ជូនកុសលទៅឱ្យទេ ពួកគេនឹងអត់បាយអត់ទឹកស្រេកឃ្លានរងទុក្ខវេទនាយ៉ាងក្រៃលែង ហើយនឹងជេរប្រទេចផ្តាសាដល់បងប្អូនញាតិកាទាំងឡាយ ទាំងប្រាំពីរសន្តាន។

បើតាមន័យនៅក្នុងគម្ពីរបេតវត្ថុ នៃគម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនានិកាយថេរវាទ ពាក្យថា *ប្រេត គឺជាបុថុជ្ជន ឬជនសាមញ្ញដែលស្លាប់រួចបានកើតជាសត្វក្នុងអបាយភូមិ ពោលគឺអបាយភូមិបេតវិស័យ ដោយសារតែពួកគេបានប្រព្រឹត្តអកុសលកម្មផ្សេងៗកាលពីនៅជាមនុស្ស។* បើពិចារណាតាមលក្ខណៈវិទ្យាសាស្ត្រ មនុស្សស្លាប់គ្មានបន្សល់អ្វីជាគ្រឿងសម្រាប់ចងចាំទេ។ ទោះបីសាច់ញាតិយកសាកសពទៅដុតកំទេចចោល យកទៅកប់ក្នុងដី បោះចោលក្នុងទឹកសមុទ្រ ឬទន្លេ ឬកាត់ចិញ្ច្រាំឱ្យត្មាតស៊ីក៏ដោយ ក៏សាកសពនោះគ្មានអ្វីសល់សេចក្តីចងចាំ ឬព្រលឹងវិញ្ញាណអ្វីឡើយ។ បើញាតិកប់ខ្មោចក្នុងដី សាច់រាងកាយនឹងផុយរលួយមុនគេ ក្រោយមកឆ្អឹងក៏នឹងរលាយទៅជាដីបាត់នៅថ្ងៃណាមួយជាប្រាកដ។ តើខ្មោចនោះមានអ្វីសេសសល់ដែលអាចរក្សាការចងចាំថាបុគ្គលនេះជាសាច់ញាតិរបស់ខ្លួន ឬមានការឈឺចាប់ ស្រេកឃ្លាន ឬខឹងសម្បារនោះ? សូម្បីមនុស្សនៅរស់ក៏មានបញ្ហាលំបាកចងចាំទៅហើយ រហូតមានជម្ងឺមួយចំនួនដែលធ្វើឱ្យអ្នកជម្ងឺបាត់បង់ការចងចាំទាំងស្រុងក៏មាន ចុះទម្រាំខ្មោចផុយរលួយខួរក្បាលគ្មានសល់ តើអាចចាំបានអ្វីខ្លះ?

ជំនឿដែលត្រឹមត្រូវមួយចំនួនត្រូវបានមនុស្សខ្លះខំផ្សារភ្ជាប់ទៅនឹងពុទ្ធសាសនានិកាយថេរវាទ គឺមិនមែនចាប់បង្ខំឱ្យមនុស្សល្ងិតល្ងង់ជឿកាន់យក និងបន្តអនុវត្តរហូតមកដល់បច្ចុប្បន្ននោះទេ គឺមានហេតុនិងផលច្បាស់លាស់។ ជំនឿដែលមានភាពប្រាកដនិយមទាំងនោះបានបន្លាចថា ជនណាដែលបានប្រព្រឹត្តអកុសលកម្មដូចជាការសម្លាប់សត្វ, ការលួចទ្រព្យគេ, ការប្រព្រឹត្តខុសក្នុងកាម, ការភូតកុហក និងការផឹកសុរាមេរ៉ៃ ពេលស្លាប់នឹងទៅកើតក្នុងភពនរក តិរច្ឆាន ប្រេត ឬ អសុរកាយ។ ពួកគេថែមទាំងបំភ័យថា ទោះមនុស្សក្រុមខាងលើនេះបានកើតជាមនុស្សក៏ដោយ ក៏បានត្រឹមតែជាមនុស្សប្រកបដោយទុក្ខវេទនា។ អ្នកសិក្សាស្រាវជ្រាវខាងសាសនានានានៅលើពិភពលោកបានរិះគន់យ៉ាងខ្លាំង ទៅលើការបង្រៀនសេចក្តីជំនឿមានលក្ខណៈប្រាកដ

និយមបែបនេះ ព្រោះថាការបង្រៀនបែបនេះគឺជាវិធីបង្រៀនដែលគ្មានមូលដ្ឋានច្បាស់លាស់តាមបែបវិទ្យាសាស្ត្រ (ឧទាហរណ៍ ចិត្តវិទ្យា) ដើម្បីឱ្យមនុស្សរៀនធ្វើអំពើល្អប្រកបដោយចិត្តមេត្តា និងករុណា។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានពុទ្ធសាសនិកជនខ្លះនៅតែជឿថាមានប្រេត មានស្ថាននរក ឬស្ថានសួគ៌ដែរដែលការជឿនេះបានធ្វើឱ្យមនុស្សលះបង់នូវទង្វើអាក្រក់ និងតង្វើបាបរបស់ខ្លួន ព្រោះខ្លាចទង្វើទាំងនោះនាំខ្លួនឱ្យទៅកើតជាប្រេតនៅពេលដែលខ្លួនបានស្លាប់ទៅ។ បើតាមការសិក្សាប្រៀបធៀបអក្សរសិល្ប៍ និងជីវភាពមនុស្សនៅក្នុងសង្គមឥណ្ឌា បានបង្ហាញថា ប្រេតគឺជាតួអង្គតំណាងប្រជារាស្ត្រក្រីក្រ ឬមនុស្សនៅក្នុងក្រុមចណ្ឌាល(ក្រៅវណ្ណៈ) ដែលទទួលរងការជិះជាន់ មើលងាយមើលថោក កេងប្រវ័ញ្ច គាបសង្កត់ បំបិតសិទ្ធិសេរីភាព ទារុណកម្ម ពីសំណាក់មនុស្សនៅក្នុងវណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ ដែលជាក្រុមមនុស្សមានអំណាច និងអ្នកដឹកនាំប្រទេស។ សម័យបច្ចុប្បន្ន នៅប្រទេសឥណ្ឌា និងនៅប្រទេសជាច្រើនទៀតដែលគ្មានការដឹកនាំតាមលទ្ធិប្រជាធិបតេយ្យ ដែលក្នុងនោះមានមនុស្សនៃវណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ (អ្នកចេះដឹង និងអ្នកមានទ្រព្យដែលគ្មានគុណធម៌) បន្តប្រព្រឹត្តអំពើអានាចារ្យ គាបសង្កត់ បោកប្រាស់រាស្ត្រក្រីក្រតាមគ្រប់រូបភាព។

## ទំនាក់ទំនងបុណ្យភ្ជុំបិណ្ឌ និងបុណ្យចូលវស្សា

បើតាមសង្ឃដីការបស់សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុម** បានឱ្យដឹងថា នៅសម័យដើមគឺ ក្រោយពេលដែលព្រះពុទ្ធសាសនាបានផ្សាយចូលមកក្នុងប្រទេសខ្មែរយើងហើយនោះ ភិក្ខុសង្ឃបាននិមន្តទៅបិណ្ឌបាតគ្រប់ច្រកល្ហករាល់ពេលវេលា ដោយមិនគិតពី រដូវវស្សា រដូវប្រាំង រដូវក្តៅ ឬរដូវរងាឡើយ។ លុះដល់សម័យស្តេចសោយរាជ្យ គឺវង្ស "ជ័យវរ្ម័ន" ព្រះអង្គមានព្រះទ័យជ្រះថ្លានឹងព្រះពុទ្ធសាសនា ក៏បានឧបត្ថម្ភព្រះសង្ឃដែលបួសក្នុងព្រះពុទ្ធសាសនា ដោយបច្ច័យបួន មានចង្ហាន់បិណ្ឌបាត្រ សេនាសណៈ ភេសជ្ជៈ និងចីវរ។ ក្រោយមកទៀត ព្រះអង្គទ្រង់ឈ្វេងយល់ថា នៅរដូវវស្សាព្រះសង្ឃនិមន្តចេញទៅបិណ្ឌបាត្រនោះត្រូវជួបប្រទះនូវការលំបាកខ្លាំងណាស់ដូចជា ភ្លៀង ផ្គរ រន្ទះ ខ្យល់បក់បោកដែលបណ្តាលឱ្យព្រះសង្ឃអង្គខ្លះត្រូវដួលលើភក់ជ្រាំនោះ ក៏នាំឱ្យព្រះអង្គកើតព្រះទ័យសង្វេគផង ជ្រះថ្លាផង ហើយក៏បានបវរណោដល់ព្រះសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យនិមន្តគង់នៅក្នុងវត្ត ហើយកុំនិមន្តចេញបិណ្ឌបាត្រឯណាក្នុងរយៈពេល៣ខែ។ មិនតែប៉ុណ្ណោះព្រះអង្គក៏បានធ្វើព្រះរាជប្រកាសផ្សព្វផ្សាយឱ្យប្រជារាស្ត្រទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ជួយឧបត្ថម្ភបច្ច័យបួនដល់ព្រះសង្ឃក្នុងរយៈពេលនៃរដូវវស្សាកុំឱ្យព្រះសង្ឃនិមន្តបិណ្ឌបាត្រនៅខាងក្រៅទៀត។ ការអនុវត្តបែបនេះ ចេះតែក្លាយបន្តិចម្តងៗ ប្រជារាស្ត្រក៏ធ្វើតាមព្រះរាជារហូតមក គឺឱ្យតែដល់រដូវវស្សា រយៈពេល៣ខែ ដោយគិតចាប់ពីថ្ងៃ១រោច ខែអាសាឍ ដល់ថ្ងៃពេញបូរមីខែអស្សុជមិនឱ្យព្រះសង្ឃទៅណាទេ (គឺនៅសម័យនោះ គេដាក់បិណ្ឌក្នុងរយៈពេល៣ខែ តែក្រោយៗមកក៏សល់រយៈពេលតិចទៅៗរហូតមកដល់សព្វថ្ងៃនេះ អាស្រ័យដោយកត្តាជីវភាពរស់នៅក្នុងសង្គមមានការប្រែប្រួល)។

សរុបសេចក្តីមក បុណ្យភ្ជុំបិណ្ឌ គឺជាពិធីបុណ្យដ៏សំខាន់ផុតមួយរបស់ខ្មែរ ដែលមានតម្លៃជាប្រវត្តិសាស្ត្រ បានបង្ហាញនូវអត្តសញ្ញាណរបស់ជាតិខ្មែរតាំងតែពីបុរាណកាលមក។ ដើម្បីឱ្យពិធីបុណ្យមួយនេះ នៅតែមានប្រជាប្រិយភាពយូរអង្វែងទៅមុខទៀតនោះ ពុទ្ធបរស័ទរួមទាំងប្រជាជនខ្មែរទាំងមូលគួរតែធ្វើអ្វីៗ កុំឱ្យឃ្លាតឆាកពីប្រពៃណីខ្មែរ កុំឱ្យឃ្លាតចាកពីក្រមសីលធម៌ គុណធម៌ សុជីវធម៌ សុភាវធម៌និងមនុស្សធម៌។ ព្រះសង្ឃ

ទាំងឡាយ គួរប្រតិបត្តិធម៌វិន័យ ឱ្យបានខ្ជាប់ខ្ជួនតាមពុទ្ធបញ្ញាតិ។ អ្នកមានធនធានទាំងឡាយ គួរតែចូលរួមក្នុងការបរិច្ចាគទានដល់ជនក្រីក្រ អ្នកកម្រត់ ទុគ៌ត អ្នកលិ្ងតល្ងង់ដែលគ្នាកំពុងមានជីវិតរស់នៅ។ មហាជនទូទៅគួរតែប្រកាន់នូវ អាកប្បកិរិយា ស្លូតបូត សុភាព រាបសារចំពោះអ្នកដទៃ។ យុវវ័យ គួរលះបង់ចេញឱ្យអស់នូវសេចក្តីខ្ជិលច្រអូស អំពើហឹង្សា ការសេពគប់មិនល្អដែល ទាំងនេះជាឫសគល់នៃការសេចក្តីវិនាសទាំងពួង។ យើងគួរតែមានធម៌មេត្តានៅក្នុងខ្លួនឱ្យបានច្រើន។ បើទោះខ្លួនជាអ្នកក្រ ឬមានក៏ដោយ គឺគួរតែតស៊ូព្យាយាមក្នុងជីវិតខិតខំសង្រួមកាយ វាចារ ចិត្ត រៀបចំការប្រព្រឹត្តរបស់ខ្លួនឱ្យបានសមសួនថ្លៃថ្នូរ និងគួរចេះចែករំលែកធនធានទៅតាមលទ្ធភាពរបស់ខ្លួន ត្រូវចេះចែករំលែកនូវចំណេះដឹងដល់អ្នកខ្សត់ខ្សោយ ព្រោះក៏ជាទានដ៏ប្រសើរមួយដែរ ហើយបើទោះបីជាខ្លួនពុំមានទ្រព្យសម្បត្តិច្រើនក៏ដោយ ឱ្យតែការប្រព្រឹត្តិរបស់ខ្លួនបានល្អ ក៏គង់នឹងមានតម្លៃ។

ដូច្នេះ បុណ្យភ្ជុំបិណ្ឌជាពិធីដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋខ្មែរ និងក្នុងវប្បធម៌ខ្មែរ ជាពិធីបុណ្យមួយក្នុងចំណោមពិធីបុណ្យធំៗជាច្រើន ដែលប្រជាពលរដ្ឋខ្មែរតែងប្រារព្ធពិធីនេះឡើងតាំងពីយូរណាស់មកហើយ ហើយរហូតមកដល់បច្ចុប្បន្ននេះ ពិធីបុណ្យភ្ជុំបិណ្ឌនេះនៅតែមានការគោរព និងប្រតិបត្តិពីប្រជាពលរដ្ឋខ្មែរជាដរាប។ ភ្ជុំបិណ្ឌនេះ មានអត្ថន័យយ៉ាងធំធេងសម្រាប់ប្រជាជាតិខ្មែរដែលជាពុទ្ធបរិស័ទ ជាឱកាសដែលមានតែម្តងក្នុងមួយឆ្នាំ គឺឱកាសនៃការជួបជុំបងប្អូនសាច់ញាតិផៅសន្តានគ្រប់ទិសទី ដើម្បីសម្តែងសេចក្តីសាទររីករាយក្នុងការធ្វើបុណ្យប្រកបដោយសទ្ធាជ្រះថ្លាក្នុងព្រះធម៌ ក្នុងការបញ្ជូនកុសលផលបុណ្យជូនចំពោះ ជីដូនជីតា និងញាតកាទាំង៧សន្តានដែលបានស្លាប់ទៅ ដែលជួនកាលពួកគាត់ក៏បានទៅកើតខ្ពង់ខ្ពស់ទៅ ជួនកាលពួកគាត់ខ្លះក៏ទៅកើតជាប្រេតទៅ ហើយនេះក៏ជាបច្ច័យមួយជួយអប់រំមនុស្សឱ្យចេះធ្វើបុណ្យ ចេះគោរពដឹងគុណ ស្គាល់គុណនិងទោស ស្គាល់ខុសនិងត្រូវ និងជួយនាំមនុស្សឱ្យមានចិត្តស្ងប់ ឱ្យចេះបរិច្ចាគ និងដាក់ទានជាដើម។ ការដែលយើងយកចង្ហាន់ទៅប្រគេនព្រះសង្ឃ និងថ្វាយព្រះក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌនៅវត្ត គឺវាមានប្រយោជន៍ដោយសារតែថា បុណ្យដែលបានធ្វើនោះ នឹងបានដល់ជីដូនជីតារបស់យើង តាមរយៈអ្នកមានសីលដែលមានព្រះសង្ឃជាតំណាង ជាអ្នកវេរបញ្ជូនទៅ ដែលក្នុងនោះមានដូចជាការរាប់បាត្រ ការបង្សុកូល ការបោះបាយបិណ្ឌ គឺសុទ្ធតែជាពិធីដែលបង្កប់នូវគុណតម្លៃនៃការគោរពដឹងងគុណ។ ទន្ទឹមនឹងការប្រារព្ធពីធីប្រកបដោយគុណតម្លៃនេះ យើងក៏សង្កេតឃើញមានយុវវ័យមួយចំនួនបានយកពិធីនេះទុកជាការលេងសើចដោយខ្លះបានយកបាយបិណ្ឌគប់គ្នាលេង ខ្លះទៀតនោះយកលេសថាទៅបោះបាយបិណ្ឌ តែបែរជាណាត់ជួបគ្នា និងទុកជាកន្លែងទាក់ទងស្នេហាទៅវិញក៏មាន ហើយមានខ្លះទៀតថាជាការបង្កិនសេដ្ឋកិច្ច ដោយការបោះបាយចោល ឬនាំឱ្យខូចបរិស្ថានជាដើម ដែលការយល់បែបនេះវាជាប្រការមួយចូលរួមចំណែកក្នុងការលុបបំបាត់នូវប្រពៃណីទំនៀមទម្លាប់ពីបុរាណរបស់ខ្មែរផងដែរ ព្រោះយើងអាចធ្វើការកែប្រែបានដោយយើងតម្រូវឱ្យមានធុង ជាល ឬល្អី សម្រាប់ដាក់ឱ្យបោះបាយបិណ្ឌទាំងនោះ ហើយបាយនោះក៏យើងអាចទៅបម្រើបម្រាស់តាមសេចក្តីត្រូវការផ្សេងៗ និងមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថានផងដែរ។ បើយើងនិយាយពីគុណសម្បត្តិនៃការបោះបាយបិណ្ឌវិញ ក៏មានច្រើនដែរ ជាពិសេសគឺការបង្កើតចិត្តមេត្តា តាមរយៈការឧទ្ទិសបាយបិណ្ឌដែលបានបោះនោះទៅដល់ប្រេត ឱ្យមកទទួលយកដុំបាយនោះ ព្រោះនៅក្នុងជំនឿ មានប្រភេទប្រេតខ្លះមិនអាចទទួលបាននូវអាហារដែលបានឧទ្ទិសនោះឡើយ ពោលគឺបានត្រឹមតែរើសយកមកហូបតែប៉ុណ្ណោះ។ ឱ្យយុវជនឧស្សាហ៍ អាចក្រោកពីដំណេកពីព្រលឹមទៅចូលរួមពិធីនេះ ហើយមិនត្រឹមតែប៉ុណ្ណោះ យុវជន យុវនារី ទាំងអស់ដែលទៅបោះបាយ

បិណ្ឌ នឹងបានចូលរួមស្តាប់ឱវាទពីព្រះសង្ឃ និងអាចារ្យ ក៏ដូចជាការចេះពីទំនៀមនៃបោះបាយបិណ្ឌ ហើយត្រូវបោះរបៀបណា គួរស្លៀកពាក់និងតុបតែងកាយ ក៏ដូចជាការៀបចំម្ហូបអាហារទៅវត្តយ៉ាងដូចម្តេច ក្នុងការបង្ហាញឱ្យបានឃើញពីអត្តសញ្ញាណខ្មែរនៃខ្លួន។ បើអ្នកដែលបានទៅធ្វើបុណ្យហើយ តែអ្នកមានចិត្តមិនស្មោះ មិនមានចិត្តជ្រះថ្លាចំពោះការធ្វើបុណ្យទេនោះ នោះអ្នកក៏មិនបានបុណ្យ និងក៏មិនបានដល់ជីដូនជីតានិងញាតកាទាំង៧សន្តានដែរ។

ធ្វើបុណ្យដោយការពិចារណានឹងបានផ្លែផ្កាដល់សង្គមជាតិ ធ្វើបុណ្យដោយងុបងល់ចោលម្សៀត នោះនឹងនាំសង្គមជាតិបាត់បង់នូវអត្តសញ្ញាណជាតិរបស់ខ្លួន សមដូចឃ្លាមួយលើកឡើងថា វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន៕

## គន្ថនិទ្ទេស

. ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ *ប្រជុំពិធីបុណ្យទាំង១២ខែ*

. សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ

. ពេជ្រ សល់ « *ពិធីប្រចាំដប់ពីរខែ* »

. សុង ស៊ីវ *ល្បើកប្រែត*

*.* នូវ សុន *សីលធម៌ ជំនឿ និងទំនៀមទម្លាប់ខ្មែរបុរាណ* ឆ្នាំ២០០៥